**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ...2865... PEAC.អក

## សេចក្តីជូនដំណឹង
## ស្តីពី

ដេញថ្លៃផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្មសាងសង់បណ្តាញអគ្គិសនីមេ 22kV ដើម្បីជួយកែលម្អប្រព័ន្ធ
បណ្តាញអគ្គិសនីមានស្រាប់ និងពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅទីតាំងចំនួន 20 តំបន់ ក្នុងខេត្តសៀមរាប

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារ និងឈ្នួលពលកម្មសាងសង់បណ្តាញអគ្គិសនីមេ 22kV ដើម្បីជួយកែលម្អប្រព័ន្ធបណ្តាញអគ្គិសនីមានស្រាប់ និងពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅទីតាំងចំនួន 20 តំបន់ ក្នុងខេត្តសៀមរាប ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី...18..... ខែ...មករា... ឆ្នាំ...2018... តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី...20..... ខែ...មីនា.... ឆ្នាំ...2018... វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង...15:30..... ថ្ងៃទី...20.... ខែ...មីនា... ឆ្នាំ...2018... ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី 14 ខែ វិច្ឆិកា ឆ្នាំ ២០១៧
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**នីវ អ៊ីង**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ